00165114

C11/38

# នៅក្នុងអង្គបុរេជំនុំជម្រះនៃ
# អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 02 / 2008
ម៉ោង (Time/Heure): 13 : 00 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## នៅក្នុងបញ្ហានៃការធ្វើបណ្តឹងឧទ្ធរណ៍ដោយនួន ជា
## ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន
## របស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧

## ស្តីអំពីបញ្ហានៃការចូលរួមដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍
## ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១)

## សារណារបស់អ៊ែន ហាញ្ញឧល ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
## ក្នុងនាមការបញ្ចេញយោបល់ផ្ទាល់ខ្លួន

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28 / 02 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## I. អ្នកផ្តល់សារណា

អ៊ែន ហាញខុល ជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ អ៊ែន ហាញខុល ធ្លាប់ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អស់រយៈពេលជាង១០ឆ្នាំ និងជាសមាជិកគណមេធាវីនៅរដ្ឋកាលីហ្វញ៉ានៃសហរដ្ឋអាមេរិក ។ យោបល់ដែលបញ្ចេញនៅក្នុងសារណានេះគឺជាយោបល់ផ្ទាល់ខ្លួន និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ សារ៉ា ថមម៉ាស (David W. Leebron International Human Rights Fellow) នៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ បានចូលរួមចំណែកក្នុងការរៀបចំសារណានេះ ។

## II. សេចក្តីសង្ខេបអំណះអំណាង

សារណានេះត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងជាសាធារណៈរបស់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អង្គជំនុំជម្រះវិសាមញ្ញ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលអនុញ្ញាតឲ្យមានការផ្តល់សារណាដោយអ្នកមិនមែនជាភាគីនៃរឿងក្តីដើម្បីដោះស្រាយបញ្ហាតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ និង សិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបរិបទនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ជនរងគ្រោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានអនុញ្ញាតឲ្យចូលរួមជាភាគីពេញលេញនៅក្នុងសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញ និង មានផលប្រយោជន៍ក្នុងការចូលរួមនៅក្នុងសវនាការផ្សេងៗមុនពេលជំនុំជម្រះពិតប្រាកដ ។ តួនាទីរបស់ជនរងគ្រោះទាំងនេះគឺខុសគ្នាខ្លះទៅនឹងតួនាទីរបស់ជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនៅក្នុងការតុលាការព្រហ្មទណ្ឌអន្តរជាតិនេះ ជនរងគ្រោះមិនមានសិទ្ធិចូលរួមពេញលេញទេ ប៉ុន្តែ ជនរងគ្រោះត្រូវដាក់ដាក់ពាក្យសុំចូលរួមនៅក្នុងដំណាក់កាលផ្សេងៗនៃដំណើរការជំនុំជម្រះ ដោយត្រូវចង្អុលបង្ហាញថាតើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេនឹងត្រូវប៉ះពាល់យ៉ាងដូចម្តេច ។ អង្គជំនុំជម្រះវិសាមញ្ញមិនគួរអនុវត្តតាមតុលាការព្រហ្មទណ្ឌអន្តរជាតិបែបនេះទេ ។ មិនមានការឯកសារណាមួយដែលតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះវិសាមញ្ញដាក់ពាក្យស្នើសុំជាថ្មីម្តងទៀតដើម្បីចូលរួមនៅក្នុងដំណាក់កាលផ្សេងៗនៃសវនាការទេ ។ វិធីដែលប្រើប្រាស់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិគឺចំណាយពេលវេលាច្រើន និង តម្រូវឲ្យមានចំណាយធនធានច្រើន ដោយតុលាការ ដោយភាគី និងដោយអ្នកចូលរួមដែលជាជនរងគ្រោះ ។

00165116



ជាងនេះទៅទៀត ភាសាប្រើនៅក្នុងធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានគាំទ្រនូវគំនិតថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមនៅគ្រប់បណ្តឹងជំទាស់របស់អង្គបុរេជំនុំជម្រះ ដែលរួមមានទាំងបណ្តឹងជំទាស់ទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្នផងដែរ ។ ចុងក្រោយបំផុត វិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់ថា ផលប្រយោជន៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះមិនមែនកំណត់ឲ្យនៅត្រឹមតែទទួលសំណងជម្ងឺចិត្តនោះទេ ប៉ុន្តែថែមទាំងមានការគាំទ្រខាងព្រះរាជអជ្ញារនៅក្នុងដំណាក់កាលស៊ើបអង្កេតផងដែរ ។ ដោយសារមូលហេតុទាំងនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីគួរតែត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងបណ្តឹងជំទាស់ទៅនឹងដីការឃុំខ្លួនបណ្តោះអាសន្ន ។

ទោះជាយ៉ាងណាក៏ដោយ ការចូលរួមដោយជនរងគ្រោះនៅក្នុងការជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញ ជានិច្ចកាល គួរតែថ្លឹងថ្លែងទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះយុត្តិធម៌ ។ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានចែងអំពីមធ្យោបាយមួយចំនួនដើម្បីថែរក្សាឲ្យមាននូវតុល្យភាពនេះ ។ ទីមួយ និយមន័យអំពីភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានកម្រិតការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមកត្រឹមតែជនរងគ្រោះដែលទទួលរងព្យសនកម្មដែល"ជាលទ្ធផលដោយផ្ទាល់ពីឧក្រិដ្ឋកម្ម ជាព្យសនកម្មដោយផ្ទាល់ ហើយព្យសនកម្មនោះបានកើតឡើងពិតប្រាកដមកដល់បច្ចុប្បន្ន" ។ បន្ទាប់ពីមានការអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ សហចៅក្រមស៊ើបអង្កេតគួរតែបញ្ជាក់ឲ្យច្បាស់ពីលក្ខណៈសម្បត្តិនេះ និងពន្យល់អំពីរបៀបដែលពួកគេបានយកមកប្រើប្រាស់ទាក់ទងនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូបដែលត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសំណុំរឿងនួន ជា ។ ទីពីរ អង្គបុរេជំនុំជម្រះគួរតែធ្វើឲ្យតឹងតែងក្នុងការតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនតុលាការជាមុននូវអំណះអំណាងនៃសវនាការណាមួយដែលពួកគេចង់ចូលរួម ដើម្បីចៀសវៀងកុំឲ្យមានការភ្ញាក់ផ្អើលដែលបង្កជាឥទ្ធិពលមិនល្អ ។ ទីបី អង្គបុរេជំនុំជម្រះគួរតែកំណត់អន្តរាគមន៍ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីឲ្យផ្តោតតែទៅលើបញ្ហាជាក់លាក់ដែលគេលើកឡើងនៅក្នុងបណ្តឹងជំទាស់ ។ ចុងបញ្ចប់ អង្គបុរេជំនុំជម្រះគួរតែជម្រុញ និងនៅពេលដែលចាំបាច់ តម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមានផលប្រយោជន៍ស្រដៀងគ្នាចូលជាក្រុម និងបញ្ចេញការយល់ឃើញរបស់ពួកគេតាមរយៈអ្នកដំណាងរួមគ្នា ដើម្បីចៀសវៀងការពន្យាពេល និងការលើកឡើងដដែលៗនៅក្នុងពេលសវនាការ ។

## III. អំណះអំណាង

## ក. វិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ជាក់លាក់នៅក្នុងសំណុំរឿងដែលពួកគេចូលរួម

១. វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញអនុញ្ញាតឲ្យជនរងគ្រោះទាំងអស់ដែលទទួលរងនូវព្យសនកម្មដោយសារឧក្រិដ្ឋកម្មមួយស្ថិតក្រោមយុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញដើម្បីអនុវត្តសិទ្ធិធ្វើបណ្តឹងរដ្ឋប្បវេណីនៅពេលដែលព្យសនកម្មរបស់ពួកគេគឺ"ផ្ទាល់ខ្លួន សម្ភារៈ ឬផ្លូវចិត្ត" និងជា "ផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្ម ជាព្យសនកម្មដោយផ្ទាល់ ហើយព្យសនកម្មនោះបានកើតឡើងពិតប្រាកដមកដល់បច្ចុប្បន្ន" ។ នៅក្នុងសវនាការបណ្តឹងជំទាស់ដីកាឃុំខ្លួនរបស់លោកនួន ពាក្យសុំតាំងខ្លួនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤ត្រូវសហចៅក្រមស៊ើបអង្កេតទទួលយល់ព្រម ។ ប៉ុន្តែ មិនមានសេចក្តីសម្រេចណាមួយធ្វើឡើងជាសាធារណៈពន្យល់អំពីរបៀបបកស្រាយលក្ខណៈសម្បត្តិ[ជ្រើសរើសភាគីដើមបណ្តឹងរដ្ឋប្បវេណី]នៅពេលធ្វើការវាយតម្លៃពាក្យសុំតាំងខ្លួនធ្វើជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬពន្យល់ពីហេតុផលដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីបំពេញបានតាមលក្ខណៈសម្បត្តិនោះទេ ។

២. ផ្ទុយទៅវិញ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលជាសាលាជំនុំជម្រះក្តីអន្តរជាតិតែមួយគត់មានចែងពីការចូលរួមដោយជនរងគ្រោះ មានសេចក្តីសម្រេចជាសាធារណៈមួយចំនួនទាក់ទងនឹងការផ្តល់និយមន័យអំពី"ជនរងគ្រោះ" ។ វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងថាទាំងរូបវន្តបុគ្គល និងនីតិបុគ្គលអាចត្រូវគេទទួលស្គាល់ថាជាជនរងគ្រោះ ។ រូបវន្តបុគ្គលត្រូវបានគេផ្តល់និយមន័យថាជាជនរងគ្រោះ នៅពេលដែលពួកគេជា"មនុស្សពិតម្នាក់ដែលទទួលរងនូវព្យសនកម្មដោយសារការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ[ព្រហ្មទណ្ឌអន្តរជាតិ]" ។ ផ្ទុយទៅវិញ នីតិបុគ្គលក៏អាចជាជនរងគ្រោះបានដែរ តែក្នុងករណីដែលពួកគេទទួលរងនូវ"ព្យសនកម្មដោយផ្ទាល់" ។ "ការប្រើប្រាស់ការបកស្រាយណាមួយ"ទៅនឹងបញ្ញត្តិទាំងនេះ អង្គជំនុំជម្រះនៃសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានកំណត់ថា "មនុស្សអាចជាជនរងគ្រោះដោយផ្ទាល់ ឬ ប្រយោល នៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ" ។

៣. ទាំងអង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះនៃសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការវិភាគលក្ខ័ណ្ឌនៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិថា ជនរងគ្រោះត្រូវតែទទួលរងនូវព្យសនកម្ម"ដែលជាលទ្ធផលនៃការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ" ។ អង្គបុរេជំនុំជម្រះបានរកឃើញថា ភាសានេះតម្រូវឲ្យមានទំនាក់ទំនងដែលបង្កជាដើមហេតុ

រវាងព្យសនកម្មដែលទទួលរងគ្រោះដោយជនរងគ្រោះ និង ឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់ ។ ប៉ុន្តែ ថ្មីៗនេះ អង្គជំនុំជម្រះនៃសាលាដំបូងបានបកស្រាយលក្ខណ្ឌនេះទូលាយជាងមុន និងបានរកឃើញថា “ជនរងគ្រោះនៃឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការអាចចូលរួមយ៉ាងសកម្ម” ប្រសិនបើគេអាចបង្ហាញទំនាក់ទំនងជាភស្តុតាងរវាងជនរងគ្រោះ និងភស្តុតាងដែលតុលាការនឹងយកមកពិចារណា ឬផលប្រយោជន៍ផ្ទាល់របស់ជនរងគ្រោះ“គឺពិតជាមានទំនាក់ទំនងនឹងបញ្ហាមួយដែលនឹងកើតឡើងនៅក្នុងដំណើរការជំនុំជម្រះ” ។

៤. ការវិភាគភាសាសរសេរនៅក្នុងវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញបានបង្ហាញថា ភាគីរដ្ឋប្បវេណីត្រូវតែទទួលរងគ្រោះព្យសនកម្ម“ដោយផ្ទាល់” “ផ្ទាល់ខ្លួន” និង“ពិតប្រាកដ” ។ ប៉ុន្តែ តាមការអនុវត្ត តើពាក្យទាំងអស់នេះមានន័យយ៉ាងណានោះគឺមិនទាន់ច្បាស់លាស់ទាំងស្រុងទេ ជាពិសេសនៅពេលប្រើប្រាស់ទៅលើសមាជិកក្រុមគ្រួសាររបស់ជនរងគ្រោះ ។ វិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក៏មិនច្បាស់លាស់ដែរទាក់ទងនឹងទំនាក់ទំនងពិសេសរវាងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ និងព្យសនកម្មដែលទទួលរងដោយជនរងគ្រោះ ។ ភាសានៅក្នុងសេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមដោយជនរងគ្រោះ(Practice Direction on Victim Participation) ដែលចែងថា “ជនរងគ្រោះនៃឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញអាចចូលរួមសវនាការក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងមួយដែលទាក់ទងនឹង*បទឧក្រិដ្ឋកម្មនោះ*” បានបង្ហាញថា អ្នកដាក់ពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញទំនាក់ទំនងជាដើមហេតុរវាងបទចោទប្រកាន់ និងព្យសនកម្មដែលទទួលរងគ្រោះពីបទឧក្រិដ្ឋដែលចោទប្រកាន់នោះ ។

៥. ដោយសារសហចៅក្រមស៊ើបអង្កេតមិនទាន់បានបញ្ចេញសេចក្តីសម្រេចចិត្តដែលវិភាគទាក់ទងនឹងប្រភេទព្យសនកម្មអ្វីដែលត្រូវតែបង្ហាញដើម្បីអាចក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងជាក់លាក់ណាមួយនោះ វាមិនទាន់ច្បាស់លាស់នៅឡើយទេថាតើសហចៅក្រមស៊ើបអង្កេតធ្វើការបកស្រាយលក្ខណៈសម្បត្តិដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងវិធានផ្ទៃក្នុងបានទូលាយ ឬ ចង្អៀតយ៉ាងណា ។ សិទ្ធិទទួលបានការជំនុំជម្រះយុត្តិធម៌របស់លោកនួន អាចត្រូវបានគេរំលោភបំពាន ប្រសិនបើគាត់មិនបានទទួលការពន្យល់អំពីមូលដ្ឋាននៃផលប្រយោជន៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួន ។ និយមន័យច្បាស់លាស់ជាក់លាក់នៃដើមបណ្តឹងរដ្ឋប្បវេណីគឺជាជំហានទីមួយយ៉ាងសំខាន់ក្នុងការថ្លឹងថ្លែងសិទ្ធិចូលរួមរបស់ជនរងគ្រោះ និងសិទ្ធិទទួលបានការជំនុំជម្រះយុត្តិធម៌ និងមិនលំអៀង ។ ដូចដែលបានលើកឡើងដោយចៅក្រមម្នាក់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ:

00165119



វាមានសារៈសំខាន់ណាស់ក្នុងការចងចាំថា ជនរងគ្រោះមិនមែនជានីតិបុគ្គល ដែលមិនមានរូបរាងនោះទេ ប៉ុន្តែជារូបវន្តបុគ្គលមានរូបរាង ឬជាក្រុមបុគ្គល ដែលបានទទួលរងនូវព្យសនកម្មនៅក្នុងករណី ឬស្ថានភាពណាមួយ ហើយសិទ្ធិ របស់ពួកគេត្រូវតែការពារ ។ មធ្យោបាយល្អបំផុតក្នុងការការពារសិទ្ធិទាំងនោះ គឺធានាថា ជាចំណុចចាប់ផ្តើមឡូហ្ស៊ិកមួយនោះ យើងបានឲ្យនិយមន័យយ៉ាង ច្បាស់លាស់ តើនរណាដែលអាចទទួលបានងារជាជនរងគ្រោះ ។ មានតែតាមរយៈ មូលដ្ឋាននោះទេទើបគេអាចគ្រប់គ្រងសិទ្ធិចូលរួមរបស់ជនរងគ្រោះបាន ។

ខ. ភាគីដើមបណ្តឹងរដ្ឋប្បវេណីអន្តជំនុំជម្រះវិសាមញ្ញមានផលប្រយោជន៍ក្នុងការចូលរួមនៅ ក្នុងបណ្តឹងជំទាស់នឹងដីការឃុំខ្លួន

១. ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនគួរតម្រូវឲ្យដាក់ពាក្យសុំចូលរួមជាច្រើនលើក ច្រើនសារនៅក្នុងសវនាការបណ្តឹងជំទាស់ដីកាឃុំខ្លួន

៦. នៅពេលដែលជនរងគ្រោះត្រូវបានគេរកឃើញថាបានបំពេញតាមលក្ខណៈសម្បត្តិរបស់ វិធានផ្ទៃក្នុងអាចចូលរួមនៅក្នុងសំណុំរឿងជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះនោះ"បានក្លាយទៅជា ភាគីមួយនៃសវនាការព្រហ្មទណ្ឌ" ដែលមានសិទ្ធិស្រដៀងគ្នាទៅនឹងសិទ្ធិរបស់ជនជាប់ចោទដែរ ដែលរួមទាំង សិទ្ធិយ៉ាងទូលំទូលាយចូលរួមនៅក្នុងដំណាក់កាលស៊ើបអង្កេត ក៏ដូចជានៅក្នុងដំណាក់កាលក្រោយៗមក ទៀតនៃការជំនុំជម្រះ ។ បើធ្វើការប្រៀបធៀប នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ជនរងគ្រោះមិន ត្រូវបានគេចាត់ទុកជាភាគី"ពិតប្រាកដ"ទេ ប៉ុន្តែ ត្រូវបានអនុញ្ញាតឲ្យបញ្ចេញ"ការយល់ឃើញ និង ការព្រួយបារម្ភ...ត្រឹមតែនៅក្នុងដំណាក់កាលនៃសវនាការដែលតុលាការសម្រេចថាសមរម្យ" នៅពេល ដែល"ផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវទទួលរងប៉ះពាល់" ។ ដូចដែលបានលើកឡើងដោយចៅក្រមអង្គជំនុំ ជម្រះនៃសាលាកំពូលម្នាក់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិៈ

> សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមដូចដែលបានចែងនៅក្នុងមាត្រា៦៨(៣) [នៃលក្ខន្តិកៈក្រុងរ៉ូម] មិនមានអ្វីល្អជាង ឬអាក្រក់ជាង ឬទំនាក់ទំនងអ្វីជាមួយ ការចូលរួមរបស់ជនរងគ្រោះនៅក្នុងសវនាការព្រហ្មទណ្ឌនៅក្នុង...ប្រព័ន្ធច្បាប់រ៉ូ ម៉ាណូ-ជ្រឺម៉ានីក ដែលនៅក្នុងប្រព័ន្ធនេះ ជនរងគ្រោះនៅក្នុងតួនាទីជាភាគីដើម

00165120

C11/38

បណ្តឹងរដ្ឋប្បវេណី ឬជាព្រះរាជអាជ្ញារងជំនួយ មានសិទ្ធិយ៉ាងទូលំទូលាយក្នុងការចូលរួមនៅក្នុងសវនាការព្រហ្មទណ្ឌ ។

៧. អង្គជំនុំជម្រះកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានរកឃើញថា ភាសាដែលមានសរសេរនៅក្នុងលក្ខន្តិកៈក្រុងរ៉ូម“ បានផ្តល់ឲ្យអង្គជំនុំជម្រះកំពូលនូវការសម្រេចចិត្តពិសេសមួយថា ការចូលរួមដោយជនរងគ្រោះគឺសមរម្យនៅក្នុងសវនាការបណ្តឹងជំទាស់ណាមួយដែលកំពុងពិចារណា” ។ ដោយសារហេតុផលនេះ ជនរងគ្រោះត្រូវតែដាក់ពាក្យសុំការអនុញ្ញាតចូលរួមនៅក្នុងសវនាការបណ្តឹងជំទាស់នោះដោយផ្តល់ជូនតុលាការនូវ“អំណះអំណាងទាក់ទងនឹងថាតើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេត្រូវប៉ះពាល់យ៉ាងដូចម្តេចនៅក្នុងសវនាការបណ្តឹងជំទាស់ណាមួយ ក៏ដូចជាថាតើហេតុអ្វីបានជាការសមរម្យដែលអង្គជំនុំជម្រះកំពូលត្រូវអនុញ្ញាតឲ្យពួកគេបញ្ចេញនូវការយល់ឃើញ និង ការព្រួយបារម្ភនៅក្នុងតុលាការ” ។ ដូច្នេះនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលខុសគ្នាពីអង្គជំនុំជម្រះវិសាមញ្ញ “ការចូលរួមគឺមិនមែនជាព្រឹត្តការណ៍ដែលធ្វើឡើងតែមួយលើករួចរាល់នោះទេ ប៉ុន្តែ ការចូលរួមគឺត្រូវតែសម្រេចទៅតាមភស្តុតាង ឬបញ្ហាដែលកំពុងពិចារណានៅក្នុងពេលវេលាជាក់លាក់ណាមួយនៅក្នុងដំណើរការ” ។ មិនមានភាសាសរសេរណាមួយដែលតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញដើរតាមតុលាការព្រហ្មទណ្ឌអន្តរជាតិនៅត្រង់បញ្ហានេះនោះទេ ជាងនេះទៅទៀត វានឹងមិនសមស្របទៅនឹងតួនាទីរបស់ភាគីរដ្ឋប្បវេណី និងតួនាទីពួកគេជាភាគីពេញលេញនោះទេ ។

៨. វាគួរឲ្យកត់សម្គាល់ថា សូម្បីតែនៅក្នុងចំណោមចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏មិនចុះសម្រុងគ្នាអំពីវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលត្រូវចំណាយពេលវេលាច្រើនទាក់ទងនឹងការចូលរួមដោយជនរងគ្រោះ ។ ជាឧទាហរណ៍ ចៅក្រមសុង(Judge Song) បានលើកឡើង ថាការដែលតម្រូវឲ្យជនរងគ្រោះបង្ហាញពីរបៀបដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេត្រូវប៉ះពាល់ម្តងហើយម្តងទៀត “បានបង្កជានីតិវិធីមិនចាំបាច់ដែលទំនងជាពន្យឺតដំណើរការជំនុំជម្រះ” ។ ជាងនេះទៅទៀត ចៅក្រមប្លេតម៉ែន(Judge Blattmann) បាននិយាយថា ការតម្រូវឲ្យមានការដាក់ពាក្យសុំជាច្រើនដង“បានដាក់បន្ទុកយ៉ាងធំធេងហួសហេតុទៅលើជនរងគ្រោះ” និងថា “វាគួរតែអាចទៅរួចដែលជនរងគ្រោះដាក់ពាក្យសុំចូលរួមពេញលេញតែម្តងនៅក្នុងពាក្យសុំដើមដំបូងរបស់ពួកគេ” ។

៩. តាមរយៈបទពិសោធន៍កន្លងមកនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ ការតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីអង្គជំនុំជម្រះវិសាមញ្ញពន្យល់អំពីផលប្រយោជន៍របស់ពួកគេនៅក្នុងគ្រប់សវនាការបុរេជំនុំ

00165121



ជម្រះ នឹងដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរទៅខាងមេធាវី និងខាងការិយាល័យព្រះរាជអាជ្ញារ ។ មានការរាយការណ៍ថា នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ គិតត្រឹមវិច្ឆិកា ឆ្នាំ២០០៧ ការិយាល័យព្រះរាជអាជ្ញារ ក្រុមមេធាវី អ្នកដំណាងជនរងគ្រោះ បានដាក់ជូនតុលាការប្រមាណជា៦០សេចក្តីថ្លែងអំណះអំណាងចំណែកឯអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះនៃសាលាកំពូល បានចេញប្រមាណជា៣០សេចក្តីសម្រេចដែលគ្រប់សេចក្តីសម្រេចនីមួយៗសុទ្ធតែដោះស្រាយសំណើរដោយជនរងគ្រោះដើម្បីចូលរួមនៅក្នុងបុរេសវនាការ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញធ្វើតាមរបៀបតុលាការព្រហ្មទណ្ឌអន្តរជាតិ សវនាការជំនុំជម្រះនឹងប្រាកដជាត្រូវពន្យាពេលជាខ្លាំង ហើយវាទំនងណាស់ដែលថាជនជាប់ចោទមួយចំនួននឹងមិនអាចនៅមានជីវិតរហូតដល់ពេលចេញសាលក្រមចុងក្រោយឡើយ ។

២. ដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ជាប់មកជាមួយតែម្តងក្នុងការចូលរួមនៅក្នុងសវនាការនៃបណ្តឹងជំទាស់ដីកាឃុំខ្លួន

១០. វិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញមិនទំនងជាបានគិតដល់ការចូលរួមដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការសួរដេញដោលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនៃសាលាដំបូងនោះទេ ។ ពួកគេក៏មិនទំនងជាអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចជុំវិញការឃុំខ្លួននោះដែរ ។ ទោះជាយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងអាចត្រូវបានគេបកស្រាយដោយមានបញ្ចូលសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងគ្រប់សវនាការលើបណ្តឹងជំទាស់របស់អង្គបុរេជំនុំជម្រះ ដែលរួមទាំងសវនាការទាក់ទងនឹងការឃុំខ្លួន ។ ជាក់ស្តែង វិធានផ្ទៃក្នុងបានចែងថា "បន្ទាប់ពីសហចៅក្រមរបាយការណ៍បានអានរបាយការណ៍[ស្តីអំពីអង្គហេតុដែលមានបញ្ហា និងការលំអិតនៃសេចក្តីសម្រេចដែលត្រូវប្តឹងឧទ្ធរណ៍] សហព្រះរាជអាជ្ញារ និងមេធាវីរបស់ភាគី អាចធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយសង្ខេប" ។

១១. គួរឲ្យកត់សម្គាល់ សូម្បីតែនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិដែលជនរងគ្រោះមិនមែនជាភាគីពេញលេញនៅក្នុងសវនាការ ជនរងគ្រោះត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសវនាការបណ្តឹងជំទាស់ទៅនឹងដីកាឃុំខ្លួន ។ នៅក្នុងសំណុំរឿងលូបាងហ្គា(Lubanga) អង្គជំនុំជម្រះសាលាកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការពិចារណាថាតើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលចូលរួមត្រូវប៉ះពាល់ដោយសារបណ្តឹងជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្នឬទេ និងបានរកឃើញថា ជនរងគ្រោះនៅក្នុងសំណុំរឿងនោះមានផលប្រយោជន៍នៅក្នុង"សវនាការបណ្តឹងជំទាស់ដែលទាក់ទងទៅនឹងការសម្រេច

ថាតើជនកំពុងស្វែងរកចាប់ខ្លួនគួរតែអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នឬទេ» ។ ការព្រួយបារម្ភដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿងនោះគឺស្រដៀងគ្នាទៅនឹងការព្រួយបារម្ភដែលកំពុងមានបញ្ហានៅក្នុងបណ្ដឹងជំទាស់របស់លោកនួនជា ដែលរួមទាំងគ្រោះថ្នាក់ដែលថា ប្រសិនបើត្រូវដោះលែងជនជាប់ចោទអាចរារាំងដល់ការស៊ើបអង្កេត ។

១២. ជាងនេះទៅទៀត ផលប្រយោជន៍ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការបញ្ចេញយោបល់អំពីបញ្ហាឃុំខ្លួនបណ្ដោះអាសន្នគឺត្រូវបានទទួលស្គាល់ដោយប្រយោលនៅក្នុងវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ បន្ថែមទៅលើការលើកឡើងអំពីផលប្រយោជន៍នៃភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការស្វែងរកសំណងជម្ងឺចិត្តផ្លូវចិត្ត និងជារួម វិធានផ្ទៃក្នុងបានសង្កត់ធ្ងន់អំពីផលប្រយោជន៍របស់ពួកគេនៅក្នុង «ការចូលរួមនៅក្នុងសវនាការព្រហ្មទណ្ឌតាមរយៈការគាំទ្រខាងព្រះរាជអាជ្ញា» ។ តួនាទីទាំងពីរនេះត្រូវបានកត់សម្គាល់ស្រដៀងគ្នាដែរនៅក្នុងសេចក្ដីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការសិទ្ធិមនុស្សអឺរ៉ុប(European Court of Human Rights) ។ ជាក់ស្ដែង អង្គជំនុំជម្រះនៃសាលាដំបូងបានសង្កត់ធ្ងន់ថា ផលប្រយោជន៍របស់ជនរងគ្រោះចូលរួមនៅក្នុងសវនាការតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺវាហួសពីការទទួលបានសំណងជម្ងឺចិត្ត និង«គួរតែរួមបញ្ចូលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងរបៀបមួយទូលាយយ៉ាងសមរម្យ» ។ នៅក្នុងសំណុំរឿងមួយទៀត ចៅក្រមអង្គជំនុំជម្រះកំពូលម្នាក់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការកត់សម្គាល់ថា លក្ខន្តិកៈក្រុងរ៉ូមបានទទួលស្គាល់ផលប្រយោជន៍របស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ដែល«ហួសពីផលប្រយោជន៍ទូទៅដែលសមាជិកសង្គមទាំងឡាយក៏អាចមានដែរនោះ ក្នុងការមើលឃើញជនល្មើសទទួលខុសត្រូវតាមផ្លូវច្បាប់» ។ លោកចៅក្រមបានរកឃើញការគាំទ្រយោបល់នេះនៅក្នុងសំណុំរឿងគីលីកនិងទួរគី (*Kilic v. Turkey*) ដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា សិទ្ធិទទួលបានដំណោះស្រាយយ៉ាងមានប្រសិទ្ធិភាព (Effective Remedy) នៅក្នុងកាតិកាសញ្ញាអឺរ៉ុប(European Convention) តម្រូវឲ្យមានៈ

> បន្ថែមទៅលើការចំណាយលើសំណងជម្ងឺចិត្តនៅពេលសមរម្យ ការស៊ើបអង្កេតយ៉ាងហ្មត់ចត់ និងមានប្រសិទ្ធិភាព ដែលអាចនាំទៅដល់ការកំណត់អត្តសញ្ញាណ និងទណ្ឌកម្មចំពោះអ្នកដែលទទួលខុសត្រូវចំពោះការដកហូតជីវិត និងដែលរួមមានទាំងសិទ្ធិយ៉ាងមានប្រសិទ្ធិភាពរបស់ម្ចាស់បណ្ដឹងក្នុងការចូលរួមក្នុងនីតិវិធីស៊ើបអង្កេត ។

00165123



១៣. ជាផលវិបាកនៃការទទួលស្គាល់របស់គាត់ចំពោះការយល់ឃើញយ៉ាងទូលំទូលាយចំពោះផលប្រយោជន៍ផ្ទាល់ខ្លួន ចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិបានរកឃើញផ្ទុយពីមតិភាគច្រើនថា ផលប្រយោជន៍របស់ជនរងគ្រោះត្រូវបានពង្រីកទៅដល់ការចូលរួមនៅក្នុងសវនាការជំនុំជម្រះលើបញ្ហាតូចតាចថាតើគួរតែអនុញ្ញាតឲ្យមានបណ្តឹងជំទាស់ទៅនឹងបទចោទប្រកាន់លើជនជាប់ចោទឬទេ ។ នៅក្នុងយោបល់របស់គាត់ នៅចុងបញ្ចប់ "បណ្តឹងជំទាស់ដែលទទួលបានជោគជ័យនឹងកាត់បន្ថយក្តីសង្ឃឹមរបស់ជនរងគ្រោះក្នុងការទទួលបានសំណងជម្ងឺចិត្ត និងទទួលបានយុត្តិធម៌" ។

១៤. ភាសាទូលាយស្រដៀងគ្នានេះដែរទាក់ទងនឹងផលប្រយោជន៍ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានផ្តល់ឲ្យដោយលក្ខណ្ឌជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាភាគីពេញលេញទៅនឹងសវនាការ និង ការទទួលស្គាល់ជាក់លាក់នៅក្នុងវិធានផ្ទៃក្នុងដែលថា ពួកគេមានផលប្រយោជន៍ក្នុងការគាំទ្រខាងព្រះរាជអជ្ញារ ។ ជាជាងការមិនអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងប្រភេទសវនាការខ្លះ ការលម្អៀងណាមួយចំពោះជនជាប់ចោទអាចត្រូវបានកាត់បន្ថយដោយការចែងឲ្យបានសមរម្យនូវទំហំនៃអន្តរាគមន៍របស់ជនរងគ្រោះ ។

## គ. ទំហំនៃសិទ្ធិក្នុងការចូលរួមក្នុងសវនាការរបស់ជនរងគ្រោះត្រូវតែថ្លឹងថ្លែងទៅនឹងសិទ្ធិទទួលបានយុត្តិធម៌របស់ជនជាប់ចោទ

១៥. នៅក្នុងសវនាការអង្គជំនុំជម្រះវិសាមញ្ញទាំងអស់ សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមត្រូវតែថ្លឹងថ្លែងទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ដែលរួមមានទាំងសិទ្ធិក្នុងការសន្មត់ជាមុនថាគ្មានទោស និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេល ។ ដូចដែលបានកត់សម្គាល់ដោយអ្នកអត្ថាធិប្បាយម្នាក់:

> ប្រសិនបើជនរងគ្រោះអាចអនុវត្តសិទ្ធិ[ចូលរួម]ដោយសេរីដោយគ្មានការកំណត់ដោយចៅក្រមនោះ សវនាការជំនុំជម្រះអាចចំណាយពេលយូរមិនអាចកំណត់បាន ដែលនាំទៅដល់ការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ ។ ចំនួនជនរងគ្រោះនៅក្នុងសំណុំរឿងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាញឹកញាប់ មានចំនួនរហូតដល់ទៅរាប់ពាន់នាក់ ឬអាចដល់រាប់ម៉ឺននាក់ទៀតផង ។ ជាងនេះទៅទៀត ចរិកនៃព្យសនកម្មដែលជនរងគ្រោះទទួលរងបានបន្ថែមទៅលើឥទ្ធិពលនៃការរំជួលចិត្តនៃអន្តរាគមន៍របស់ពួកគេនៅក្នុងសវនាការ ។

00165124



> ប្រសិនបើមិនមានការគ្រប់គ្រងនោះទេ ការចូលរួមរបស់ពួកគេអាចធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តដ៏រលូននៃការជំនុំជម្រះ និង ដល់សិទ្ធិរបស់ជនជាប់ចោទ ក៏ដូចជាការស្វែងរកការពិត ។

*១. អង្គបុរេជំនុំជម្រះគួរតែគ្រប់ករណីទាំងអស់តម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនតុលាការជាមុននូវសេចក្តីសន្និដ្ឋានដែលនឹងលើកឡើងនៅក្នុងពេលសវនាការ*

១៦. ដើម្បីការពារកុំឲ្យមានការលម្អៀងចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ នៅមុនពេលសវនាការលើបណ្តឹងជំទាស់ អង្គបុរេជំនុំជម្រះគួរតែតម្រូវយ៉ាងតឹងរឹងឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនតុលាការជាមុននូវអំណះអំណាងដែលពួកគេបម្រុងនឹងលើកឡើងនៅក្នុងពេលសវនាការ ដូចដែលតម្រូវឲ្យធ្វើដូច្នេះដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារ (Practice Direction on the Filing of Documents) ។ ការមិនគោរពតាមលក្ខណ្ឌនេះនៅក្នុងសវនាការបណ្តឹងជំទាស់របស់លោកនួន អង្គបុរេជំនុំជម្រះបានប្រថុយប្រថានក្នុងការលម្អៀងទៅលើសិទ្ធិរបស់ជនជាប់ចោទ និង បានបើកឱកាសឲ្យខាងមេធាវីអាចធ្វើការជំទាស់ផ្ទាល់មាត់ភ្លាមៗទៅនឹងការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដោយមិនបានដាក់អំណះអំណាងពីដំបូងជូនតុលាការ ។

*២. អង្គបុរេជំនុំជម្រះគួរតែដាក់កម្រិតអន្តរាគមន៍ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីមកនៅត្រឹមតែចំណុចបញ្ហាជាក់លាក់ដែលប្តឹងជំទាស់*

១៧. អង្គជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញគួរតែដាក់កម្រិតផងដែរលើសេចក្តីសន្និដ្ឋានដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីមកនៅត្រឹមតែផ្តោតលើបញ្ហាដែល«ទាក់ទងជាពិសេសទៅនឹងចំណុចប្តឹងជំទាស់ជាជាងសេចក្តីសន្និដ្ឋានដែលផ្តោតជាទូទៅ» ។ ជាក់ស្តែង អង្គជំនុំជម្រះកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានតម្រូវឲ្យជនរងគ្រោះដែលចូលរួមបង្ហាញពី«ទំនាក់ទំនងរវាងសេចក្តីសន្និដ្ឋានរបស់ពួកគេទៅនឹងបញ្ហាដែលកំពុងត្រូវប្តឹងជំទាស់» ។ អង្គជំនុំជម្រះកំពូលនេះបានថ្លែងថា៖

> វាជារឿងមិនសមរម្យទេដោយគ្រាន់តែលើកឡើងដដែលម្តងទៀតនូវភស្តុតាងដែលមានរួចហើយនៅក្នុងអង្គបុរេជំនុំជម្រះ ឬ ដោយបង្ហាញភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះកំពូល ដោយមិនមានបង្ហាញអំពីទំនាក់ទំនងថាតើភស្តុតាង

ថ្មីនេះអាចមានឥទ្ធិពលដូចម្តេចខ្លះទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះជុំវិញបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងជំទាស់ ។

ជាងនេះទៅទៀត នៅពេលដែលចំណុចដែលជនរងគ្រោះបានលើកឡើងមិនបានផ្តល់ជាជំនួយដល់សេចក្តីសម្រេចលើបញ្ហាដែលត្រូវប្តឹងជំទាស់ អង្គជំនុំជម្រះកំពូលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនយកចំណុចទាំងនេះជាមូលដ្ឋានក្នុងការសម្រេចទេ ។

១៨. ការកំណត់កម្រិតទាំងនេះគឺជារឿងត្រឹមត្រូវសូម្បីតែទាក់ទងទៅនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី បើទោះបីជាភាគីដើមបណ្តឹងរដ្ឋប្បវេណីជាភាគីពេញលេញទៅនឹងការជំនុំជម្រះក្តីក៏ដោយ ។ ជាក់ស្តែង តុលាការសិទ្ធិមនុស្សអឺរ៉ុបបានទទួលស្គាល់ថា ទំហំនៃសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមសវនាការតុលាការអាចត្រូវបានកំណត់ «ដោយពិនិត្យមើលអំពីតួនាទីនៃបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ និងអំពីផលប្រយោជន៍បន្ទាប់បន្សំនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី និងខាងព្រះរាជអាជ្ញា... តួនាទី និងគោលបំណងរបស់ពួកគេគឺខុសគ្នាយ៉ាងច្បាស់ក្រឡែត» ។ ប៉ុន្តែ «ការកំណត់កម្រិតទាំងនេះត្រូវតែមិនកំហិត ឬកាត់បន្ថយសិទ្ធិចូលរួមរបស់បុគ្គលតាមរបៀបបែបនោះ ឬដល់កម្រិតដែលត្រូវប៉ះពាល់សិទ្ធិរបស់ពួកគេនោះទេ» ។ ជាងនេះទៅទៀត ការកំណត់កម្រិតណាមួយត្រូវតែមានគោលបំណងសមស្របតាមច្បាប់ និងមាន«ទំនាក់ទំនងសមហេតុសមផលនៃសមាមាត្ររវាងមធ្យោបាយប្រើប្រាស់ និងគោលដៅដែលចង់សម្រេចឲ្យបាន» ។

១៩. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា ភាគីរឿងក្តីទាំងអស់មានសិទ្ធិ«ដាក់សេចក្តីសន្និដ្ឋានដែលពួកគេយល់ថាជាប់ពាក់ព័ន្ធនឹងសំណុំរឿងរបស់ពួកគេ» ហើយតុលាការមាន«កាតព្វកិច្ចពិនិត្យមើលសេចក្តីសន្និដ្ឋាន អំណះអំណាង និងភស្តុតាងដែលដាក់ជូនដោយភាគី» និងផ្តល់ហេតុផលចំពោះសេចក្តីសម្រេចរបស់ពួកគេ ។ ទោះបីជាយ៉ាងនេះក៏ដោយ តុលាការអាចធ្វើការវាយតម្លៃថាតើសេចក្តីសន្និដ្ឋានរបស់ភាគីទាក់ទងនឹងរឿងក្តីឬអត់ និង មិនចាំបាច់ផ្តល់«ចម្លើយពិស្តារ»ទៅគ្រប់អំណះអំណាងនោះវិញទេ ។

**៣. អង្គជំនុំជម្រះអាចតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីជ្រើសរើសអ្នកតំណាងជារួមម្នាក់**

២០. វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានចែងថា «ភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមអាចជ្រើសរើសមេធាវីមួយរូបធ្វើជាអ្នកតំណាងចេញពីបញ្ជីឈ្មោះមេធាវីដែលចេញដោយអង្គភាពជនរងគ្រោះ» ។ ជាងនេះទៅទៀត សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចរៀបចំការធ្វើតំណាងនេះដោយៈ (១). ស្នើសុំឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីជ្រើសរើសមេធាវីរួមគ្នា (២). ស្នើសុំឲ្យអង្គភាពជនរងគ្រោះជ្រើសរើសមេធាវីរួមមួយសម្រាប់ពួកគេ (៣). «នៅពេលដែលគេយល់ថាយុត្តិធម៌តម្រូវឲ្យពួកគេធ្វើដូច្នោះ» [សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះខ្លួនឯង] ចាត់តាំងមេធាវីតំណាងរួមឲ្យក្រុមនោះតែម្តង ។

២១. អំណាចក្នុងការរៀបចំភាគីដើមបណ្តឹងរដ្ឋប្បវេណីជាក្រុមនេះបានផ្តល់ឲ្យតុលាការនូវមធ្យោបាយយ៉ាងសំខាន់ដែលអាចស្វែងរកតុល្យភាពសមរម្យរវាងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ ។ មកទល់នឹងពេលនេះ យើងមិនទាន់ដឹងថាមានជនរងគ្រោះប៉ុន្មាននាក់ដែលនឹងដាក់ពាក្យបណ្តឹងសុំធ្វើភាគីដើមបណ្តឹងរដ្ឋប្បវេណី និងថាតើប៉ុន្មាននាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាដើមបណ្តឹងរដ្ឋប្បវេណី ។ ទោះជាយ៉ាងណាក៏ដោយ បទឧក្រិដ្ឋកម្មដែលត្រូវបានចោទទៅលើជនជាប់ចោទជាក់ស្តែង មានជនរងគ្រោះរាប់លាននាក់ ហើយសវនាការអាចមានចំនួនភាគីដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើននៅក្នុងរយៈពេលនៃការដំណើរការជំនុំជម្រះនេះ ។ ដូចដែលទទួលស្គាល់ដោយអង្គជំនុំជម្រះនៃសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិថា «ករណីដែលជនរងគ្រោះមានចំនួនច្រើនខ្លាំងពេកលេចមុខនោះអាចធ្វើឲ្យប៉ះពាល់ដល់ល្បឿន និងភាពត្រឹមត្រូវនៃការជំនុំជម្រះ» និងបង្កជាការពន្យាពេលយ៉ាងខ្លាំង ។ ដោយសារមូលហេតុនេះ ប្រសិនបើភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំចូលរួមនៅក្នុងសំណុំរឿងនៃអង្គជំនុំជម្រះវិសាមញ្ញ អង្គជំនុំជម្រះអាចជម្រុញ និងក្នុងករណីដែលចាំបាច់តម្រូវឲ្យមានការបែងចែកជាក្រុម ជាយន្តការចាំបាច់ដើម្បីធានាឲ្យបាននូវប្រសិទ្ធិភាព និងភាពត្រឹមត្រូវនៃការជំនុំជម្រះ ដោយមិនភ្លេចពីផលប្រយោជន៍បុគ្គលនៃភាគីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗនោះទេ ។

២២. វិធានផ្ទៃក្នុងបានចែងថា «សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ និងអង្គភាពជនរងគ្រោះ នឹងចាត់វិធានការណ៍សមហេតុសមផលទាំងអស់ដើម្បីធានាថា នៅក្នុងការជ្រើសរើសមេធាវីផលប្រយោជន៍ដោយឡែកៗពីគ្នានៃភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេតំណាងឲ្យ និងថា វិសមិទ្ធិភាពមិនកើតមានទេ» ។ បញ្ញត្តិស្រដៀងគ្នានេះក្នុងការរៀបចំជនរងគ្រោះជាក្រុមតាមរយៈអ្នកតំណាងរួមក៏មានចែងនៅក្នុងវិធាននីតិវិធី និងភស្តុតាង(Rules of Procedure and Evidence) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរ ។ នៅក្នុងសេចក្តីសម្រេចថ្មីៗនេះ អង្គជំនុំជម្រះនៃសាលាដំបូងបាន

គាំទ្រ"មធ្យោបាយទន់ភ្លន់មួយ"ក្នុងការរៀបចំជាក្រុម និងបានកំណត់យោបល់ដូចតទៅនេះថាមានសារៈសំខាន់នៅក្នុងពេលជ្រើសរើសៈ "ភាសាដែលជនរងគ្រោះនិយាយ(និងអ្នកតំណាងណាមួយដែលត្រូវបានស្នើរមកដោយជនរងគ្រោះ), ទំនាក់ទំនងរវាងជនរងគ្រោះដូចជាពេលវេលា ទីកន្លែង និងស្ថានភាព, និងប្រភេទនៃបទឧក្រិដ្ឋដែលពួកគេគិតថាបានទទួលរងគ្រោះ" ។

២៣. ជាពិសេស នៅពេលដែលមានការជំទាស់ពីដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមអាចតម្រូវឲ្យមានការរៀបចំជាក្រុមតែនៅពេលដែលពួកគេគិតថា"ភាពយុត្តិធម៌"តម្រូវឲ្យធ្វើដូច្នោះ ។ ដូច្នេះ រហូតដល់ពេលដែលការរៀបចំចូលជាក្រុមនេះជារឿងចាំបាច់មែនទែននោះ គេគួរតែជម្រុញឲ្យមានការចូលជាក្រុមដោយការស្ម័គ្រចិត្ត ដើម្បីជៀសវៀងការលើកឡើងដដែលនៅក្នុងពេលសវនាការ ។ ទន្ទឹមនោះដែរ អង្គជំនុំជម្រះអាចរកឃើញថា វាជារឿងចាំបាច់ក្នុងដាក់កំហិតឲ្យតែអ្នកតំណាងឲ្យក្រុម ឬសមាជិកក្រុមតែម្នាក់ ឬច្រើនជាងនេះប៉ុណ្ណោះអាចធ្វើការអះអាងដោយផ្ទាល់មាត់នៅក្នុងពេលសវនាការ ប្រសិនបើចំនួននៃការលើកឡើងនៅក្នុងពេលសវនាការនេះអាចបង្កជាការពន្យាពេលច្រើន ឬ អាចបង្កជាការលម្អៀងដល់ជនជាប់ចោទ ។

## IV. សេចក្តីសន្និដ្ឋាន

២៤. ដោយសារអង្គជំនុំជម្រះវិសាមញ្ញទំនងជាឱកាសតែមួយគត់ដែលជនរងគ្រោះអាចប្រឈមមុខនឹងអ្នកដែលធ្វើបាបពួកគេនិងក្រុមគ្រួសាររបស់ពួកគេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នករួចរស់ជីវិតពីរបបនោះរាប់ពាន់នាក់ប្រហែលជាអាចដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ។ ការចូលរួមបែបនេះអាចជាការរួមចំណែកយ៉ាងសំខាន់ដល់ដំណើរការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែ ទំហំនៃអន្តរាគមន៍ដោយដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែចាត់ចែងឲ្យបានប្រុងប្រយ័ត្នបំផុតដោយអង្គជំនុំជម្រះ បើមិនដូច្នោះទេ ការជំនុំជម្រះនេះអាចបាត់បង់ការផ្តោតអារម្មណ៍ និងអាចបង្កជាការពន្យាពេលជាខ្លាំង ដែលការណ៍នេះអាចនាំទៅដល់ការកាត់បន្ថយគោលបំណងនៃផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ពោលគឺជួយដល់ខាងព្រះរាជអជ្ញារ និងទទួលបានយុត្តិធម៌ ។

ដោយការគោរពយ៉ាងខ្ពង់ខ្ពស់

អ៊ែន ហាញខូល
ទីប្រឹក្សាច្បាប់
មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ ១១១០
ភ្នំពេញ, ប្រទេសកម្ពុជា
៨៥៥ (០)២៣ ២១១ ៨៧៥

ចុះហត្ថលេខានៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៨